

MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# ការប្ដេជ្ញាចិត្តអំពី
# ការបញ្ជ្រាបយេនឌ័រទៅក្នុងការអភិវឌ្ឍធនធានទឹក
# នៅអាងទន្លេមេគង្គក្រោម

## កម្ពុជា - ឡាវ - ថៃ - វៀតណាម
## សំរាប់ការអភិវឌ្ឍដោយនិរន្តរភាព



# គោលនយោបាយ
# និងយុទ្ធសាស្ត្រយេនឌ័រ

នៅគណៈកម្មការទន្លេមេគង្គ ការសម្រេចបានតុល្យភាព រវាងទិដ្ឋភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន កាន់តែមានសារៈសំខាន់ឡើងៗ ។ ការពិចារណាអំពីទិដ្ឋភាពផ្នែកសង្គម ត្រូវបានកំណត់ថា ជាគោលដៅមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រសំខាន់ៗទាំងឡាយ ដែលបង្កើតជាមូលដ្ឋានគោលនៃទស្សនៈវិស័យរបស់គណៈកម្មការទន្លេមេគង្គសម្រាប់អាងទន្លេមួយដែលប្រកបដោយវិបុលភាពផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម និងប្រកបដោយបរិស្ថានល្អ។ ការពិចារណាអំពីទិដ្ឋភាពផ្នែកសង្គម ជាចំណុចដែលត្រូវគិតគូរអោយបានដិតដល់ក្នុងការសម្រេចអោយបាននូវគោលដៅអភិវឌ្ឍន៍ និងការធ្វើផែនការប្រើប្រាស់ធនធានធម្មជាតិ។ ក្នុងចំណោមការពិចារណាទាំងអស់ យេនឌ័រ គឺជាបញ្ហាអាទិភាពដែលត្រូវតែគិតគូរ។ សម្រាប់ប្រទេសដែលជាសមាជិកគណៈកម្មការទន្លេមេគង្គ យេនឌ័រ គឺជាបញ្ហាអាទិភាពមួយនៃអាទិភាពជាតិទាំងឡាយ ដើម្បីបង្កើតសមធម៌សេដ្ឋកិច្ច និងផលប្រយោជន៍សង្គម សំរាប់សកម្មភាពអភិវឌ្ឍន៍។ យេនឌ័រត្រូវបានគេរាប់ចូលថាជាកត្តាអថេរផ្នែកសេដ្ឋកិច្ច និង សង្គមដ៏ចម្បងមួយដែលមានសារជាតិប្រទាក់ក្រឡាជាមួយនឹងវិស័យផ្សេងៗទៀត ហើយដែលចាំបាច់ត្រូវគិតគូរដោយយកចិត្តទុកដាក់នៅក្នុងរាល់ទិដ្ឋភាពទាំងអស់នៃកម្មវិធីអភិវឌ្ឍន៍របស់គណៈកម្មការទន្លេមេគង្គ។

ក្នុងន័យនេះ គោលនយោបាយ និងយុទ្ធសាស្ត្រយេនឌ័ររបស់គណៈកម្មការទន្លេមេគង្គ ត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩៨ និង អនុម័តនៅឆ្នាំ ២០០០ ដោយប្រទេសជាសមាជិកតាមរយៈក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ។

# គោលនយោបាយយេនឌ័ររបស់ គណៈកម្មការទន្លេមេគង្គ

## សនិទានភាពសំរាប់ គោលនយោបាយយេនឌ័ររបស់ គណៈកម្មការទន្លេមេគង្គ

ការគ្រប់គ្រងធនធានទឹកចម្រុះប្រកបដោយជោគជ័យ ត្រូវការវិធីដោះស្រាយប្រទាក់ក្រឡាគ្នាគ្រប់វិស័យ សំរាប់ការធ្វើផែនការសំរាប់ការអភិវឌ្ឍ ការប្រើប្រាស់ និងសំរាប់ការការពារធនធានទឹក ។ វិធីសាស្ត្រដោះស្រាយបែបចម្រុះនេះភ្ជាប់ទិដ្ឋភាពស្ថាប័ន ទិដ្ឋភាពគ្រប់គ្រង ទិដ្ឋភាពសង្គម ទិដ្ឋភាពយេនឌ័រ និង ទិដ្ឋភាពសេដ្ឋកិច្ចជាមួយនឹងការវិភាគបច្ចេកទេស និងការដោះស្រាយបញ្ហា។ វិធីសាស្ត្រភ្ជាប់ទិដ្ឋភាពដែលទាក់ទងគ្នានេះផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍមួយដែលឆ្លើយតបនឹងតម្រូវការខុសៗគ្នារបស់ស្ត្រី និងបុរសដោយឈរលើមូលដ្ឋានស្មើភាពគ្នា ។

ដោយផ្អែកលើយុទ្ធសាស្ត្រយេនឌ័រនេះ គោលបំណងនៃគោលនយោបាយយេនឌ័រ គឺដើម្បីកំណត់វិធីដោះស្រាយចំបងរបស់គណៈកម្មការទន្លេមេគង្គ លើបញ្ហាយេនឌ័រក្នុងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ ។

